# ជំពូកទី ១០: សន្និដ្ឋាន និង អនុសាសន៍

## ១០.១ សន្និដ្ឋាន

គំរោងវារីអគ្គិសនីស្ទឹងតាតៃ គឺជាវារីអគ្គិសនីដែលមានខ្នាតធំ និងបានស្នើធ្វើឡើងនៅលើស្ទឹងតាតៃក្នុងទឹកដីស្រុកថ្មបាំង និងស្រុកកោះកុង ខេត្តកោះកុង។ សមត្ថភាពតំឡើងសរុបគឺ ២៤៦ MW ជាមួយនឹងសមត្ថភាពផលិតថាមពលប្រចាំឆ្នាំបាន ៨៥៨.១៤ GWh និងចំនួនម៉ោងប្រើប្រាស់ប្រចាំឆ្នាំ ៣៤៨៨ ម៉ោង។ **គំរោងវិនិយោគនេះគឺជាប្រភេទ BOT ជាមួយ នឹងរយៈពេលប្រតិបត្តិការដែលបានស្នើរឡើង ៣៧ឆ្នាំ និងតំលៃវិនិយោគសរុបគឺ ៥៤០ លានដុល្លា សហរដ្ឋអាមេរិក។** គំរោងវារីអគ្គិសនីស្ទឹងតាតៃដែលបានស្នើរឡើង គឺជាគំរោងការអភិវឌ្ឍន៍ថាមពលដែលឆ្លើយតប ទៅនឹងផែនការមេសំរាប់ការអភិវឌ្ឍន៍វិស័យថាមពលនៅក្នុងឆ្នាំ ២០១៨ របស់ប្រទេសកម្ពុជា ។

ក្នុងការអនុវត្តន៍គំរោង នឹងមានការខូចខាត ព្រៃឈើ និងជំរកសត្វព្រៃ ប្រហែលជា ៣000 ha នៅក្នុងតំបន់នោះ និងបានរំពឹងគិតថា មានផលប៉ះពាល់មធ្យមដល់សត្វព្រៃនៅក្នុងដំណាក់កាលសាងសង់ ដោយសារការបាត់បង់ជំរករបស់ពួកវា និង មានការរំខានដល់ផ្លូវបំលាស់ទីរបស់ពួកវា (ជាពិសេសសត្វដំរី) និងសកម្មភាពសាងសង់ផ្សេងៗទៀត។ ប៉ុន្តែវាមានការប៉ះពាល់បន្តិចបន្តួចទៅលើសត្វព្រៃរាប់ទាំងពពួកមច្ឆជាតិ/វារីសត្វផ្សេងទៀតនៅក្នុងដំណាក់កាលប្រតិបត្តិការ។ គំរោងនឹងបង្កឱ្យមានហេតុប៉ះពាល់មធ្យមដល់លំហូរទឹក និងគុណភាពទឹក ក្នុងពេលការសាងសង់ និងរយៈពេលពីរបីឆ្នាំដំបូង ក្នុងដំណាក់កាលការប្រតិបត្តិគំរោង។ គំរោងនេះនឹងមានការប៉ះពាល់បន្តិចបន្តួចដល់ធនធានសង្គម ដូចជា សុខភាពសាធារណៈ និងជីវភាពរបស់គ្រួសារមួយចំនួននៅក្នុងតំបន់គំរោងរស់នៅអាស្រ័យលើអនុផលព្រៃឈើ និងសត្វព្រៃ។ ពុំមានការផ្លាស់ប្តូរទីលំនៅដ្ឋាន សូម្បីតែមួយគ្រួសារ ដោយសារការអនុវត្តន៍គំរោងនេះទេ។

បណ្តុំនៃហេតុប៉ះពាល់ នឹងកើតមានឡើងផងដែរក្នុងអំឡុងពេលការសាងសង់និងប្រតិបត្តិការគំរោង ពីបន្សំរួមគ្នានៃរោងចក្រវារីអគ្គិសនីនៅក្នុងតំបន់ត្រីកោណរវាងខេត្ត កំពង់ស្ពឺ កោះកុង និងពោធិសាត់ ព្រមទាំងគំរោងផ្សេងទៀតនៅក្នុងតំបន់ឆ្នេរនៃខេត្តកោះកុងផងដែរ។ បណ្តុំហេតុប៉ះពាល់រួមមាន: អាកាសធាតុ របបជលសាស្ត្រ ព្រៃឈើ ជំរកសត្វព្រៃ និងសត្វព្រៃ។

អាចសន្និដ្ឋានបានថា គំរោងនឹងបង្កហេតុប៉ះពាល់អវិជ្ជមានមធ្យមដល់ព្រៃឈើ សត្វព្រៃនៅក្នុងស្រុកថ្មបាំង និងស្រុកកោះកុង ហើយនិងប៉ះពាល់ដល់លំហូរទឹកនៅ ខ្សែទឹកខាងក្រោមនៃទំនប់។ មានផលប៉ះពាល់តិចតួចដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដែលត្រូវបានបង្កឡើងដោយសារគំរោង។ ក៏ប៉ុន្តែដោយការអនុវត្តន៍ត្រឹមត្រូវតាមវិធានការកាត់បន្ថយដែលបានរៀបចំឡើង និងផែនការគ្រប់គ្រងបរិស្ថានដែលបានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន អាចបន្ធូបន្ថយហេតុប៉ះពាល់អវិជ្ជមានទាំងនោះបានមួយចំនួនធំ។ ទោះបីយ៉ាងណាក៏ដោយ គំរោងនឹងផ្តល់ផលប៉ះពាល់ជាវិជ្ជមានទៅដល់ប្រជាជាតិកម្ពុជា ដូចជា ការផ្តល់ថាមពលដែលជឿជាក់យ៉ាងច្រើន (៨៥៨.១៤



Draft

GWh/ឆ្នាំ) និងថាមពលមានតំលៃថោក ជាងថាមពលដែលនាំចូលពីប្រទេសជិតខាង និងថាមពលផលិតពីម៉ាស៊ីនភ្លើងដុតប្រេងឥន្ធនៈ។ ការធ្វើឱ្យប្រសើរឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធនៅក្នុងស្រុកថ្មបាំង (ផ្លូវ ស្ពាន លូរំដោះទឹក) ផ្តល់ការងារដល់ប្រជាជនក្នុងមូលដ្ឋានរាប់ពាន់នាក់នៅក្នុងអំឡុងពេលនៃការសាងសង់។ តាមរយៈលទ្ធផលនៃការផលិតថាមពលប្រចាំឆ្នាំយ៉ាងសន្ធឹកសន្ធាប់នេះ នឹងផ្តល់ផលវិជ្ជមានដល់ការអភិវឌ្ឍន៏សេដ្ឋកិច្ចកម្ពុជា តាមរយៈសកម្មភាពជាច្រើន រួមមានៈ ឧស្សាហកម្ម/សិប្បកម្ម កសិកម្ម និងទេសចរណ៍នៅក្នុងតំបន់ព្រមទាំងនៅទូទាំងប្រទេសផងដែរ។ ការកើនឡើងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងទូទាំងប្រទេសពីសកម្មភាពលូតលាស់លើវិស័យទាក់ទិននានា។ គំរោងនឹងបង់ពន្ធទៅរាជរដ្ឋាភិបាលកម្ពុជាផ្នែក តាមកិច្ចព្រមព្រៀងវិនិយោគ និង កាតព្វកិច្ចច្បាប់របស់ប្រទេសកម្ពុជា។

ដូចនេះ គំរោងវារីអគ្គិសនីស្ទឹងតាតៃ គឺជាគំរោងមួយក្នុងគំរោងមានអាទិភាពមួយចំនួន ដែលបានឆ្លើយតបទៅនឹងតំរូវការអគ្គិសនីរបស់ប្រទេសក្នុងឆ្នាំខាងមុខៗនេះ ព្រមទាំងមានលទ្ធភាព/ប្រសិទ្ធិភាព បច្ចេកទេស សេដ្ឋកិច្ច និងទិដ្ឋភាពបរិស្ថាន។ ការអនុវត្តន៏គំរោងស្ទឹងតាតៃនឹងផ្តល់ការគាំទ្រជាច្រើន ដល់និន្នាការកំនើនសេដ្ឋកិច្ចកម្ពុជា និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនទូទាំងប្រទេស។

## ១០.២ អនុសាសន៍

តាមការវាយតំលៃហេតុប៉ះពាល់ឃើញថា គំរោងនឹងបង្កការប៉ះពាល់ដល់ធនធានបរិស្ថាន និងសង្គមមួយចំនួនក្នុងតំបន់ ដូចនេះអនុសាសន៏សំខាន់ៗមួយចំនួន ដូចខាងក្រោម នឹងត្រូវអនុវត្តដើម្បីធានាបាននូវការការពារធនធានបរិស្ថានសំរាប់ចីរភាពនៃការអភិវឌ្ឍន៏ប្រទេសជាតិៈ

- កំរិតកំពស់ទឹកលិចនៅក្នុងអាងស្តុក មិនឱ្យខ្ពស់ជាង ២១៥ (ធៀបនឹងនីវ៉ូទឹកសមុទ្រ)។
- យ៉ាងហោចណាស់ ការបញ្ចេញទឹកពីគំរោងឱ្យបាន ៣ $m^3/s$ . ក្នុងករណីផ្អាកដំណើរការ គឺដើម្បីថែរក្សាប្រព័ន្ធអេកូឡូស៊ីនៅខ្សែទឹកខាងក្រោមឱ្យនៅមានជីវិត ។
- គុណភាពទឹកនៅក្នុងអាងស្តុកទឹក និងនៅខ្សែទឹកខាងក្រោមរបស់គំរោង គឺត្រូវបានត្រួតពិនិត្យឱ្យបានទៀងទាត់ នឹងត្រូវមានវិធានការសមស្រប នៅពេលដែលគុណភាពទឹកបានធ្លាក់ចុះ ដែលបណ្តាលមកពីគំរោង ។
- ដើមឈើដែលមានតំលៃនៅក្នុងតំបន់អាងស្តុកទឹក ត្រូវកាប់យកចេញ និងប្រើសំរាប់គោលបំណងផ្សេងៗ មុនពេល ដែលអាងស្តុកទឹកត្រូវបានពន្លិច ដោយមានការចូលរួមពីរដ្ឋបាលព្រៃឈើ និងស្ថាប័នទទួលខុសត្រូវ។
- ការដុតឈើតូចៗ មែកឈើ ស្លឹកឈើ មួយចំនួននៅក្នុងផ្ទៃអាង ត្រូវតែអនុវត្ត ដោយមានការចូលរួមពីរដ្ឋបាលព្រៃឈើ និងស្ថាប័នទទួលខុសត្រូវ ដើម្បីការបន្ថយការបំពុលគុណភាពទឹក ។
- ក្រុមហ៊ុនត្រូវតែចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារតំបន់ព្រៃ និងជំរកសត្វព្រៃសំខាន់ៗដែលនៅសល់ក្នុងតំបន់។
- គ្រប់វិធានការកាត់បន្ថយទាំងអស់ ដែលបានផ្តល់ជាអនុសាសន៏នៅក្នុងផែនការគ្រប់គ្រងបរិស្ថាននៃរបាយការណ៍សិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានខាងលើ ត្រូវតែអនុវត្តឱ្យបានពេញលេញ។

Draft

ក្រុមហ៊ុន CTHL មានសេចក្តីរីករាយនឹងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យអគ្គិសនីនៅកម្ពុជា និងគោរពតាមច្បាប់វិនិយោគ និងច្បាប់នានានៃកិច្ចការពារបរិស្ថានរបស់ប្រទេសកម្ពុជា។ ទន្ទឹមនេះក្រុមហ៊ុន CTHL មានសំណូមពរដល់ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធទាំងអស់ ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជាមេត្តាជួយបង្កលក្ខណៈងាយស្រួល និងចេញលិខិតអនុញ្ញាតលើការសិក្សា វ.ហ.ប ពេញលេញ អោយក្រុមហ៊ុនស្របទៅតាមច្បាប់វិនិយោគ និងច្បាប់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឱ្យបានទាន់ពេលវេលាដែលបានគ្រោងទុក។

រាជធានីភ្នំពេញ. ថ្ងៃទី..12..ខែ...10.....ឆ្នាំ ២០១០

CTHL-**ក្រុមហ៊ុនវិនិយោគ**

**លោក Zhu Xu**

រាជធានីភ្នំពេញ. ថ្ងៃទី...12...ខែ....10......ឆ្នាំ ២០១០

KCC- **ក្រុមហ៊ុនរៀបចំរបាយការណ៍** EIA

**អគ្គនាយក**

**លោក សោម មិថុនារត្ន័**

Draft